 គម្រោង វណ្ណ ម៉ូលីវណ្ណ
THE VANN MOLYVANN PROJECT

# *គម្រោង វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ ២០១៥*
# *សេចក្តីប្រកាសព័ត៌មាន*

**មាតិកាសម្រាប់ការប្រកាសព័ត៌មាន**


១. អំពីលោក វណ្ណ ម៉ូលីវណ្ណ
២. អំពីចលនាស្ថាបត្យកម្មខ្មែរថ្មី
៣. អំពី *គម្រោងវណ្ណម៉ូលីវណ្ណ*
៤. អំពី *គម្រោងវណ្ណម៉ូលីវណ្ណ៖ រដូវក្តៅ ២០១៥*
៥. អំពីគេហទំព័ររបស់ *គម្រោងវណ្ណម៉ូលីវណ្ណ*
៦. កម្មវិធីសាធារណៈ
៧. អ្នកចូលរួមក្នុងគម្រោង
៨. អំណរគុណចំពោះដៃគូផ្តល់មូលនិធិ
៩. ព័ត៌មានលម្អិតអំពីពិពណ៌
១០. អំពី ស ស បាសាក់
១១. ទំនាក់ទំនង
១២. ការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយកន្លងមក




**The National Sports Complex (Olympic Stadium), Phnom Penh under construction, 1963. Collection Vann Molyvann**

# អំពីលោក វណ្ណ ម៉ូលីវណ្ណ

លោក វណ្ណ ម៉ូលីវណ្ណ គឺជាស្ថាបត្យករនាំមុខគេនិងផលិតស្នាដៃជាច្រើន នៅក្នុងចលនាស្ថាបត្យកម្មខ្មែរថ្មីរបស់ប្រទេសកម្ពុជា។

លោក វណ្ណ ម៉ូលីវណ្ណ កើតក្នុងខេត្តកំពត ក្នុងឆ្នាំ១៩២៦។ ក្នុងឆ្នាំ១៩៤៦ គាត់បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង។ គាត់បានសិក្សាផ្នែកស្ថាបត្យកម្មរួមជាមួយផ្នែកសិល្បៈផ្សេងទៀតនៅសាលាវិចិត្រសិល្បៈ និងបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាដែលទើបទទួលបានឯករាជ្យថ្មីៗក្នុងឆ្នាំ១៩៥៦។ បន្តិចក្រោយមក គាត់ត្រូវបានសម្តេចនរោត្តមសីហនុតែងតាំងជាស្ថាបត្យកររដ្ឋ។ គាត់បានបន្តរចនាគម្រោងសាធារណៈដែលត្រូវបានគេស្គាល់និងធំធេងបំផុតរបស់ប្រទេសកម្ពុជាដែលសាងសង់ឡើងជាចំណែកមួយនៃទំនើបនីយកម្មទូទាំងប្រទេសដែលបានចាប់ផ្តើមដោយរបបសង្គមរាស្ត្រនិយម។ គាត់ក៏បានរចនាលំនៅដ្ឋានឯកជននិងរចនាសម្ព័ន្ធតូចៗជាច្រើននៅក្នុងសម័យនេះដែរ។

បន្ថែមពីលើការងារជាច្រើនរបស់គាត់ក្នុងនាមជាស្ថាបត្យករ លោក វណ្ណ ម៉ូលីវណ្ណ ក៏ជាអ្នកធ្វើផែនការទីក្រុង និងគ្រប់គ្រងការពង្រីកក្រុងភ្នំពេញ ក៏ដូចជាការបង្កើតកំពង់ផែសមុទ្រក្រុងព្រះសីហនុ (កំពង់សោម) និងនៅទីតាំងផ្សេងៗទៀត។ ជាងនេះទៀត គាត់ក៏បានចូលរួមនៅក្នុងការងារដឹកនាំសាកលវិទ្យាល័យវិចិត្រសិល្បៈ និងបានបោះពុម្ពផ្សាយអត្ថបទជាច្រើនស្តីពីទំនើបភាវូបនីយកម្មប្រទេសកម្ពុជានៅក្នុងព្រឹត្តិប័ត្រស្រាវជ្រាវជាភាសាខ្មែរជាច្រើន។ គាត់ត្រូវបានគេចងចាំជាបុគ្គលនាំមុខគេក្នុងជីវិតវប្បធម៌យ៉ាងសកម្មនៅក្នុងសម័យក្រោយឯករាជ្យរបស់ប្រទេសកម្ពុជាដែរ។

បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ ដែលបានទម្លាក់សម្តេចសីហនុនិងរបស់ព្រះអង្គ លោកវណ្ណ ម៉ូលីវណ្ណ បានផ្លាស់ទៅរស់នៅក្នុងប្រទេសស្វីស។ ក្នុងរយៈប៉ុន្មានទសវត្សក្រោយមក គាត់បានបន្តការងាររបស់គាត់ជាមួយកម្មវិធីតាំងទីលំនៅរបស់មនុស្សរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាអន្តរជាតិ។

ក្នុងឆ្នាំ១៩៩១ លោកវណ្ណម៉ូលីវណ្ណ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនិងត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ វិចិត្រសិល្បៈ ការធ្វើផែនការក្រុងនិងប្រទេស។ គាត់គាត់ជះឥទ្ធិពលយ៉ាងសំខាន់ក្នុងការបង្កើតអាជ្ញាធរអប្សរា ដែលជាអង្គភាពពហុបក្សសហប្រតិបត្តិការគ្នាដែលមានបំណងក្នុងក្នុងការគ្រប់គ្រងឃ្លាំមើលការស្រាវជ្រាវនិងរដ្ឋបាលប្រាសាទបុរាណតំបន់អង្គរ។ គាត់ក៏បានបន្តការស្រាវជ្រាវ បោះពុម្ពផ្សាយសៀវភៅជាច្រើននិងបញ្ចប់ថ្នាក់បណ្ឌិតផ្នែកប្រវត្តិសាស្ត្រការតាំងទីលំនៅរបស់មនុស្សក្នុងតំបន់អាស៊ីអាគ្នេយ៍។

បច្ចុប្បន្ននេះ លោកវណ្ណម៉ូលីវណ្ណ រស់នៅជាមួយភរិយារបស់គាត់ ក្នុងខេត្តសៀមរាបក្នុងប្រទេសកម្ពុជា។

## អំពីចលនាស្ថាបត្យកម្មខ្មែរថ្មី

លោក វណ្ណ ម៉ូលីវណ្ណ គឺអ្នកចេញមុខនិយាយនាំមុខគេនិងផលិតស្នាដៃជាច្រើន នៃសាលារចនាសំណង់នៅទូទាំងប្រទេស ដែលគេស្គាល់ថាជាស្ថាបត្យកម្មខ្មែរថ្មី។ វិធីសាស្ត្រដ៏ពិសេសនេះក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងឱកាសរបស់សំណង់ក្រោយសម័យអាណានិគមនិយម បានជះឥទ្ធិពលពាសពេញប្រទេសកម្ពុជា ទាំងនៅទីក្រុងនិងតំបន់ជនបទ អស់ពេលជាច្រើនឆ្នាំបន្ទាប់ពីទទួលបានឯករាជ្យ (១៩៥៣) និងមុនការគ្រប់គ្រងរបស់ខ្មែរក្រហម (១៩៧៥)។ លោកវណ្ណម៉ូលីវណ្ណ មិនមែនជាអ្នកតស៊ូមតិតែម្នាក់ឯងនោះទេ បុគ្គលសំខាន់ផ្សេងៗទៀតរួមមានដូចជា លូបានហាប់ និង ម៉មសុផាណា។

ស្ថាបត្យកម្មខ្មែរថ្មី អាចត្រូវបានកំណត់លក្ខណៈដោយ៖

- ការប្រើប្រាស់សម្ភារៈសំណង់ថ្មី ជាចម្បងគឺ reinforced concrete
- ការយោងផ្អែកទស្សន៍និងរចនាសម្ព័ន្ធ តាមបច្ចេកទេសសំណង់របស់កម្ពុជាដែលមានពីមុន ជាពិសេសការលើកជន្ទល់ទម្រអាគារ
- ការយល់ដឹងសម្របតាមអាកាសធាតុតំបន់ត្រូពិច ដែលបង្ហាញតាមរយៈការប្រើប្រាស់ចរន្តខ្យល់ធម្មជាតិនិងការធ្វើម្លប់ដោយភាពច្នៃប្រឌិត
- ការប្រើប្រាស់សម្ភារៈតុបតែងដោយសន្សំសំចៃ ជាពិសេសក្បាច់ចម្លាក់ដែលជះឥទ្ធិពលដោយការតុបតែងប្រាសាទសម័យអង្គរ។

រួមជាមួយនឹងការទាញចេញពីទម្រង់សំណង់កម្ពុជាដែលមានពីមុនមកនេះ ចលនាស្ថាបត្យកម្មខ្មែរថ្មី ក៏បានចូលរួមជាមួយនឹងទំនើបនិយមអន្តរជាតិផ្សេងៗជាច្រើនទៀត។ ស្ថាបត្យករនិងវិស្វករមកពីជប៉ុន អឺរ៉ុប អតីតសហភាពសូវៀត សហរដ្ឋអាមេរិច និងមកពីកន្លែងផ្សេងទៀត បានចូលរួមជាមួយជនកម្ពុជា ធ្វើការលើគម្រោងសំខាន់ៗជាច្រើន ដោយរាប់បញ្ចូលទាំងវិស្វករដ៏មានឥទ្ធិពលឈ្មោះ Vladimir Bodiansky ទៀតផង។ ដូច្នេះ ចលនាស្ថាបត្យករខ្មែរថ្មី អាចត្រូវបានគេយល់ថា មិនត្រឹមតែជាការធ្វើសម្របទៅតាមតំបន់នៃទំនើបនិយម "រចនាបថអន្តរជាតិនោះទេ" ប៉ុន្តែវាថែមទាំងជាការចេរចារមួយរវាងវិធីសាស្ត្ររចនាផ្សេងៗពីប្រភពផ្សេងៗ។

ក្រោមការដឹកនាំដ៏សកម្មរបស់សម្តេចសីហនុ គម្រោងសាធារណៈដ៏មានមហិច្ឆតាជាច្រើនពាសពេញប្រទេសកម្ពុជាបានក្លាយទៅជាឱកាសបង្ហាញស្នាដៃសម្រាប់ស្ថាបត្យកម្មខ្មែរថ្មី ដោយរាប់បញ្ចូលទាំងស្ថាប័នអប់រំនិងវប្បធម៌ផង។ ប៉ុន្តែ រចនាបទថ្មីពិសេសនេះ ក៏ត្រូវបានពលរដ្ឋក្រសោបយកដោយក្តីសោមនស្សផងដែរ ហើយស្ថាបត្យកម្មខ្មែរថ្មីត្រូវបានប្រើសម្រាប់ការសង់លំនៅដ្ឋានឯកជនប្រកបដោយប្រជាប្រិយភាពទៀតផង។

ចលនាស្ថាបត្យកម្មខ្មែរថ្មីនាពេលបច្ចុប្បន្ននេះ ត្រូវបានគេចងចាំថាជាចំណែកត្របាញ់បញ្ចូលគ្នានៃសមិទ្ធិផលវប្បធម៌ដែលមានលក្ខណៈច្នៃប្រឌិត ក្នុងសម័យក្រោយទទួលបានឯករាជ្យ។ អាគារទំនើបប្លែករបស់ស្ថាបត្យកម្មខ្មែរថ្មី បានក្លាយទៅជាឆាកសម្រាប់ភាពយន្តខ្មែរជាច្រើនដែលផលិតដោយឧស្សាហកម្មភាពយន្តកម្ពុជាដែលមានការរីកចម្រើយយ៉ាងរហ័សក្រោយឆ្នាំ១៩៦០, តន្ត្រីរ៉ក់ខិនរ៉ូលបានបន្ទរសម្លេងឡើងនៅក្នុងលំហរបស់អាគារទាំងនោះ, ជញ្ជាំងត្រូវបានតុបតែងដោយផ្ទាំងគំនូររចនា

បទថ្មី, អ្នករស់នៅបានស្លៀកពាក់សម្លៀកបំពាក់សម័យថ្មីដែលរួមបញ្ចូលជាតុផ្សំអឺរ៉ុបនិងជាតុផ្សំក្នុងស្រុក។

ដូចគ្នានឹងទម្រង់វប្បធម៌ទាក់ទងគ្នានេះដែរ ស្ថាបត្យកម្មខ្មែរថ្មី សម្តែងចេញនូវព្រលឹងនៃពេលវេលារបស់ខ្លួននៅក្នុងវិធីសាស្ត្រដ៏ពិសេសរបស់ខ្លួនចំពោះកាលៈទេសៈក្នុងស្រុក។

សម្រាប់ព័ត៌មាននិងរូបភាពបន្ថែមទៀតនៃស្ថាបត្យកម្មខ្មែរថ្មី សូមចូលទៅកាន់៖ nka.lumhor.org

## អំពី *គម្រោង វណ្ណ ម៉ូលីវណ្ណ*

*គម្រោង វណ្ណ ម៉ូលីវណ្ណ* គឺជាក្រុមស្ថាបត្យករនិងនិស្សិតផ្នែកស្ថាបត្យកម្មអន្តរជាតិមួយកំពុងធ្វើការនៅទីក្រុងភ្នំពេញ ដើម្បីចងក្រងឯកសារអំពីអាគាររបស់លោកវណ្ណ ម៉ូលីវណ្ណ។

គម្រោងនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩ ដោយស្ថាបត្យករជនជាតិកាណាដាឈ្មោះ Bill Greaves ដើម្បីធ្វើការស្ទង់មតិ គូរ រៀបចំជាឯកសារ ប្រមូលបណ្ណាសារ បោះពុម្ពផ្សាយ និងលើកកំពស់ការយល់ដឹងអំពីអាគារវិសាមញ្ញទាំងនេះ ដែលពេលបច្ចុប្បន្ននេះ ត្រូវទទួលរងការគំរាមកំហែងដោយការពុកផុយនិងការអភិវឌ្ឍន៍។

ស្នាដៃរបស់លោក ម៉ូលីវណ្ណ បង្កើតបានជាការប្រមូលផ្តុំមួយនៃការប្រមូលផ្តុំសំខាន់បំផុតជាច្រើននៃអាគារក្រោយសម័យអាណានិគមនិយម នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងមានសារៈសំខាន់បំផុតចំពោះមរតកស្ថាបត្យកម្មទំនើបក្នុងប្រទេសកម្ពុជា។ នៅក្រោមការគ្រប់គ្រងរបស់សម្តេចនរោត្តមសីហនុ, លោក វណ្ណម៉ូលីវណ្ណ បានធ្វើឲ្យក្រុងភ្នំពេញផ្លាស់ប្តូរមុខមាត់តាមរយៈការរចនាអាគារព្រឹទ្ធសភា ពហុកីឡដ្ឋានជាតិ សាលមហោស្រពជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី សាលសន្និសីទចតុមុខ និងអាគាររដ្ឋាភិបាល អាគារសិក្សាស្រាវជ្រាវ អាគារស្ថាប័នអាគារឧស្សាហកម្ម និងអាគារបែបលំនៅដ្ឋានច្រើនជាង៦០អាគារផ្សេងទៀត ពាសពេញផ្ទៃប្រទេស។

អាគារដ៏វិសេសវិសាលទាំងអស់នេះ បានទទួលរងការគំរាមកំហែងដោយភាពពុកផុយនិងការអភិវឌ្ឍន៍ ហើយកម្រិតដែលប្រទេសកម្ពុជាកំពុងបាត់បង់អាគារទាំងនោះ កំពុងតែមានសភាពកាន់តែលឿនឡើង។ ក្នុងឆ្នាំ២០០៨ ស្នាដៃដ៏មហិមារបស់លោកវណ្ណម៉ូលីវណ្ណចំនួនពីរ គឺមហោស្រពជាតិ និងក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីត្រូវបានកំទេចចោល។ ការកំទេចនេះ មិនមែនជាការគំរាមតែមួយគត់នោះទេ។ ដោយសារតែការគូរស្ទើរតែទាំងអស់របស់លោកវណ្ណម៉ូលីវណ្ណត្រូវបានបំផ្លាញបន្ទាប់ពីគាត់ត្រូវបានបង្ខំឲ្យភៀសខ្លួនពីប្រទេសក្នុងឆ្នាំ១៩៧១នោះ គេក៏មិនមានឃើញសល់ដានថាតើអាគារណាមួយត្រូវកំទេចនោះទេ។ *គម្រោងវណ្ណម៉ូលីវណ្ណ* នេះនឹងដោះស្រាយស្ថានភាពបន្ទាន់នេះ។

បេសកកម្មរបស់*គម្រោង វណ្ណ ម៉ូលីវណ្ណ* មានបី៖

១. បំពេញកង្វះខាតក្នុងការធ្វើកំណត់ត្រាប្រវត្តិសាស្ត្រ តាមរយៈការធ្វើការប្រមូលទិន្នន័យអំពីអាគារដែលនៅសល់ និងការបង្កើតប្រព័ន្ធទិន្នន័យមួយអំពីគំនូសវាស់វែង

២.លើកកម្ពស់ប្រវត្តិស្ថាដែនិងកេលម្ពលទ្ធភាពក្នុងការអភិរក្សតាមរយៈការតាំងពិពណ៌និងការបោះពុម្ពផ្សាយឲ្យបានទៅដល់ប្រជាជនកម្ពុជាដែលនៅក្រៅប្រទេសនិងទៅដល់កម្រិតអន្តរជាតិ។

៣.បង្កើតឲ្យមានកិច្ចសហប្រតិបត្តិការរវាងស្ថាបត្យករនិងនិស្សិតខ្មែរនិងបរទេស ដោយភ្ជាប់ពួកគេទៅនឹងឧទាហរណ៍ដ៏វិសេសវិសាលនៃមរតកទំនើបរបស់ប្រទេសកម្ពុជា និងផ្តល់នូវមូលដ្ឋានសម្រាប់សម្ភារៈអប់រំដែលមានគុណតម្លៃមិនចេះចប់នៅក្នុងប្រទេសកម្ពុជា និងនៅកន្លែងផ្សេងទៀត។

ស្ទូឌីយ៉ូស្រាវជ្រាវដំបូងនៅក្នុងឆ្នាំ២០០៩-១០ ក្នុងក្រុងភ្នំពេញ ត្រូវបានបន្តដោយការតាំងពិពណ៌ម៉ូដែល គំនូរស្ថាបត្យកម្ម និងសម្ភារៈផ្សេងទៀតដែលបានរៀបចំឡើងនៅមជ្ឈមណ្ឌលវប្បធម៌បារាំង នៅភ្នំពេញ (២០១០) និងនៅអាកាយានដ្ឋានអន្តរជាតិភ្នំពេញ (២០១១)។ ម៉ូដែលទាំងនោះក៏ត្រូវបានដាក់បង្ហាញនៅសាកលវិទ្យាល័យន័រតុន នៅភ្នំពេញ (២០១១-២០១៥) ហើយនឹងត្រូវដាក់បង្ហាញនៅមជ្ឈមណ្ឌលខេមរសិក្សា នៅខេត្តសៀមរាប (ចុងឆ្នាំ ២០១៥ ទៅមុខ)។

## *អំពី គម្រោង វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ ២០១៥*

បើកពីថ្ងៃអង្គារដល់ថ្ងៃសៅរ៍ ពីម៉ោង១០ព្រឹក ដល់៥ល្ងាច ពីថ្ងៃទី៨ មិថុនា ដល់ ៥ កញ្ញា ២០១៥។

ក្រោមការដឹកនាំដោយស្ថាបត្យករនិងអ្នកស្រាវជ្រាវទីក្រុង ឈ្មោះ ប៉ែន សេរីបញ្ញា *គម្រោងវណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ២០១៥* នៅ ស ស បាសាក់ នឹងដើរតួនាទីជាស្ថាបត្យកម្មតម្លាភាពនិងស្ទូឌីយ៉ូស្រាវជ្រាវមួយ ដែលរចនាឡើងដើម្បីឲ្យមានការចូលរួមពីនិស្សិតនិងអ្នកទស្សនា។ ទស្សនិកជនទៅ ស ស បាសាក់ នឹងបានចូលរួមក្នុងដំណើរការនៃកិច្ចសហប្រតិបត្តិការ ការស្រាវជ្រាវ ការប្រមូលបណ្ណាសារ និងការសាងសង់ ជុំវិញគោលការណ៍របស់លោក វណ្ណ ម៉ូលីវណ្ណ, ស្ថាបត្យកម្មខ្មែរថ្មី, ប្រវត្តិសាស្ត្រការអភិវឌ្ឍន៍ទីក្រុង, និងការងារធ្វើគម្រូអតីតកាលនិងបច្ចេកវិទ្យាស្ថាបត្យកម្មបច្ចុប្បន្ន។

គម្រោង វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ២០១៥ គឺជាការស្រាវជ្រាវដែលមានរយៈពេលបីខែ ដែលធ្វើឡើងដោយក្រុមនិស្សិតស្ថាបត្យកម្មកម្ពុជានិងអ្នកស្រាវជ្រាវអន្តរជាតិមួយក្រុម ព្រមទាំងបើកដល់សាធារណជនក្នុងការមកទស្សនានិងចូលរួម។ ដោយធ្វើការរួមគ្នានេះ ពួកគេនឹងធ្វើការងារដូចខាងក្រោម៖

- ពង្រីកប្រព័ន្ធទិន្នគំនូរស្ថាបត្យកម្មអាគារមានការកត់ត្រារួចដែលមានស្រាប់។ ការចងក្រងឯកសារបន្ថែមទៀត នឹងរួមមានបញ្ចូល៖ វិទ្យាស្ថានប៉ាស្ទ័រ រោងភាពយន្តកាពីតូល ទីតាំងសាកលវិទ្យាល័យភ្នំពេញ ធនាគារជាតិ ក្រុងព្រះសីហនុ រាជដំណាក់ ក្រុងព្រះសីហនុ។
- បំលែងគំនូរដែលបញ្ចប់ហើយពីប្រព័ន្ធទិន្នន័យកម្មវិធី CAD ទៅជាបណ្ណាសារជាកម្មវិធី

PDF ដែលអាចរកបានតាមប្រព័ន្ធអ៊ីនធឺណែត www.vannmolyvannproject.org ដោយមានឯកសារឹងនៅមជ្ឈមណ្ឌលខេមរសិក្សា។ សម្ភារៈទាំងនេះនឹងប្រើជាមូលដ្ឋានសម្រាប់ការពិពណ៌និងការបោះពុម្ពផ្សាយក្នុងពេលអនាគត ដូចមានរៀបរាប់ខាងក្រោម

- ផលិតម៉ូដែលរូបវន្តថ្មីមួយអំពីពហុកីឡដ្ឋានជាតិ ដោយផ្អែកលើគំនូរដែលមានស្រាប់របស់យើង
- សម្ភាសនិងកត់ត្រាប្រវត្តិសាស្រ្តផ្ទាល់មាត់អំពីអ្នករស់នៅក្នុងនិងប្រើប្រាស់អាគាររបស់លោក វណ្ណម៉ូលីវណ្ណ
- ផលិតម៉ូដែលសម្រាប់ធ្វើដំណើររៀបចំពិពណ៌ទាំងនៅថ្នាក់ជាតិនិងអន្តរជាតិ

ទស្សនិកជនមកកាន់គម្រោង *វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ២០១៥* ត្រូវបានអញ្ជើញឲ្យមើលការការពិពណ៌ដែលបង្ហាញពីការប្រែប្រួលជាបន្តបន្ទាប់អំពីគម្រូស្ថាបត្យកម្ម ការគូរ ផ្នែកព័ត៌មាន និងផែនទី និងសង្កេតមើលដំណើរការនៃការជ្រើសរើសនិស្សិតពីសាកលវិទ្យាល័យវិចិត្រសិល្បៈ និងសាកលវិទ្យាល័យន័រតុននៅភ្នំពេញ និងសាលារចនាថ្មី Parsons ពេលពួកគេសហការគ្នាធ្វើការបញ្ចប់ទៅលើការធ្វើការអង្កេតទៅលើអាគារនិងបង្កើតជាប្រព័ន្ធទិន្នន័យជាសាធារណៈមួយទៅលើ ការគូរដែលត្រូវបានវាស់វែង ការស្រាវជ្រាវប្រវត្តិសង្គម តាមរយៈការសម្ភាសន៍និងប្រវត្តិសាស្រ្តផ្ទាល់មាត់របស់អ្នករស់នៅទីនោះ និងអ្នកប្រើប្រាស់អាគាររបស់លោក វណ្ណ ម៉ូលីវណ្ណ ហើយនៅស្ទូឌីយ៉ូពួកគេសាងសង់ម៉ូដែលកីឡដ្ឋានអូឡាំពិក។ បរិបទនិងបទពិសោធន៍បន្ថែមទៀត ក៏ត្រូវបានផ្តល់ជូននៅក្នុងបន្ទប់អាននិងបន្ទប់ភាពយន្ត ក៏ដូចជាកម្មវិធីសាធារណៈរបស់យើងនៅទីកន្លែងផ្ទាល់និងមិននៅទីកន្លែងផ្ទាល់។

## អំពីគេហទំព័ររបស់ *គម្រោង វណ្ណ ម៉ូលីវណ្ណ*

អំពី *គម្រោង វណ្ណ ម៉ូលីវណ្ណ ក្នុងឆ្នាំ២០១៥* នឹងបើកសម្ពោធជាធនធាន "ប្រភពបើកចំហរ" ថ្មីប្រកបដោយមហិច្ឆតាមួយ ដែលអាចរកបានដោយសេរីសម្រាប់ស្ថាបត្យករ និស្សិត អ្នកស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជានិងលើឆាកអន្តរជាតិតាមរយៈគេហទំព័រ www.vannmolyvannproject.org។ រាល់គំនូរនិងសម្ភារៈផ្សេងៗទាំងអស់ដែលបង្កើតឡើងតាំងពីការចាប់ផ្តើមគម្រោងក្នុងឆ្នាំ២០០៩ នឹងអាចរកបានសម្រាប់ការទាញយកដោយសេរីមិនគិតកម្រៃនៅពេលចប់*គម្រោង វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ ២០១១៥* ។ គេហទំព័រនេះក៏នឹងមានដាក់បញ្ចូលប្រព័ន្ធទិន្នន័យប្រវត្តិសាស្រ្តផ្ទាល់មាត់មួយដែរ។

## កម្មវិធីសាធារណៈ អំពី *គម្រោង វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ ២០១៥*

*គម្រោង វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ ២០១៥* បើករៀងរាល់ថ្ងៃពីថ្ងៃអង្គារដល់ថ្ងៃសៅរ៍ ពីម៉ោង ១០ព្រឹក ដល់ម៉ោង ៥រសៀល។ ទស្សនិកជនអាចមកបាននៅពេលណាក៏បាន ដើម្បីមើលស្នាដៃដែល

កំពុងរីកចម្រើន ចូលមើលក្នុងបណ្ណាល័យរបស់គម្រោង និងមើលការពិពណ៌វិវត្តនៃម៉ូដែលនិងគំនូរស្ថាបត្យកម្ម។

បន្ថែមពីលើការបើកសម្រាប់ទស្សនិកជនជារៀងរាល់ថ្ងៃ គម្រោងនេះក៏ស្វាគមន៍ទស្សនិកជនក្នុងការចូលរួមក្នុងព្រឹត្តិការណ៍ពិសេសៗដូចខាងក្រោម៖

**កាលវិភាគសម្រាប់កម្មវិធី**

**<u>ការចាប់ផ្តើម</u>**

ថ្ងៃសៅរ៍ ទី១៣ មិថុនា | ម៉ោង៦.០០-៨.០០ល្ងាច
នៅ ស ស បាសាក់
ផ្ទះលេខ១៨២ ផ្លូវសុជារស ភ្នំពេញ

**<u>ការធ្វើបទបង្ហាញ</u>**

សម្រាប់ទាំងសាធារណជនទូទៅ និងសម្រាប់និស្សិតស្ថាបត្យកម្មនៅក្នុងសាកលវិទ្យាល័យនាំមុខគេនៅក្នុងទីក្រុងភ្នំពេញ លោក ប៉ែនសេរីបញ្ញា នឹងផ្តល់នូវបទបង្ហាញអំពីការណែនាំបទបរិបទប្រវត្តិសាស្ត្រអំពីលោកវណ្ណម៉ូលីវណ្ណ និងស្នាដៃរបស់គាត់ ព្រមទាំងគោលដៅនៃការបង្កើតគម្រោងនិងសកម្មភាពកំពុងធ្វើក្នុងគម្រោងវណ្ណម៉ូលីវណ្ណនេះ និងគម្រោង *វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ* ២០១៥។ ជាភាសាខ្មែរនិងមានការបកប្រែជាភាសាអង់គ្លេស។

ថ្ងៃសុក្រ ទី១៩ មិថុនា | ម៉ោង២.០០-៤.០០ រសៀល
សាកលវិទ្យាល័យន័រតុន, មហាវិទ្យាល័យស្ថាបត្យកម្ម
ផ្លូវលេខ១១៨ ជ្រោយចង្វា ភ្នំពេញ

ថ្ងៃអង្គារ ទី២២ មិថុនា | ម៉ោង៩.០០-១១.០០ ព្រឹក
សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, មហាវិទ្យាល័យស្ថាបត្យកម្ម
អាគារលេខ៧២ ផ្លូវលេខ១៩ ភ្នំពេញ

**<u>ការបញ្ចាំង</u>**

ថ្ងៃសៅរ៍ ទី១៨ កក្កដា | ម៉ោង៥.០០-៦.៣០ ល្ងាច
មជ្ឈមណ្ឌលធនធានសោតទស្សន៍បុផាណា
ផ្ទះលេខ៦៤ ផ្លូវ២០០ ឧកញ៉ាម៉ែន ភ្នំពេញ

*ទិដ្ឋភាពភ្នំពេញ៖ មុននិងអំឡុងសម័យសង្គមរាស្ត្រនិយម*

ល្ងាចនេះ នឹងនាំយកមកការជ្រើសរើសពីបណ្ណាសាររបស់មជ្ឈមណ្ឌលបុផាណា ដោយផ្តោតលើទិដ្ឋភាពក្រុងភ្នំពេញមុននិងក្នុងអំឡុងសម័យសង្គមរាស្ត្រនិយម (១៩៥៥ ដល់ ១៩៧០)។ ការបង្ហាញ

អំពីការប្រមូលផ្តុំរូបថតដ៏កម្រ ដោយបុគ្គលដែលមានឆន្ទៈក្នុងការចងក្រងឯកសារអំពីរាជធានីនេះ រួមមាន Mami Palgen (១៩៤២ ដល់ ១៩៦២) និង Adolf Sherl (១៩៦៦ ដល់ ១៩៧០), ព្រមទាំងវីដេអូខ្លីៗមិនមានឈ្មោះអំពីការជិះកាត់តាមទីក្រុងក្នុងឆ្នាំ១៩៤៥ និងការងារនៅការដ្ឋានសាងសង់ព្រលានយន្តហោះក្នុងឆ្នាំ១៩៥៨។ កម្មវិធីនេះនឹងបញ្ចប់ជាមួយនឹងការបញ្ចាំងឯកសារ *កម្ពុជាឆ្នាំ១៩៦៥* ដែលជាភាពយន្តឯកសារផលិតឡើងដោយសម្តេចនរោត្តមសីហនុក្នុងការលើកម្ពស់ចក្ខុវិស័យនៃ "ការរីកចម្រើន" ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច អប់រំ សុខភាពសាធារណៈ កសិកម្ម និងឧស្សាហកម្ម ក្នុងអំឡុងសម័យសង្គមរាស្ត្រនិយម។ ជាភាសាខ្មែរនិងមានបកប្រែជាភាសាអង់គ្លេស។

ថ្ងៃសុក្រ ទី២១ សីហា | ម៉ោង៧.០០ ល្ងាច
ផ្ទះមេត្តា/មជ្ឈមណ្ឌលវប្បធម៌អាឡឺម៉ង់-កម្ពុជា
ផ្ទះលេខ៣៧ មហាវិថីសម្តេចសុធារស ភ្នំពេញ

*Concrete Visions* ដោយ Nico Mesterharm (២០០៩, ១៧ នាទី)
"វាជាការពិបាកក្នុងការស្រមៃអំពីជោគវាសនារបស់អ្នកធ្វើផែនការទីក្រុងម្នាក់ដែលមានភាពឃោរឃៅជាងការឃើញប្រទេសរបស់ខ្លួនត្រូវបានគ្រប់គ្រងដោយរបបមួយដែលមានការស្អប់ខ្ពើមទីក្រុងជាទីបំផុតនោះ។ ក្នុងនាមជាស្ថាបត្យករដ៏ល្បីល្បាញនិងជាអ្នកធ្វើផែនការទីក្រុងដ៏កំពូលម្នាក់ក្នុងអំឡុងទសវត្សឆ្នាំ១៩៦០នោះ លោកវណ្ណម៉ូលីវណ្ណ បានរៀបចំផ្នែកសំខាន់ៗជាច្រើននៅទីក្រុងភ្នំពេញ និងបានរចនាអាគារសំខាន់ៗ ដោយបានបញ្ចូលគ្នារវាងការរចនាបែបទំនើបខ្ពស់ជាមួយនឹងធាតុផ្សំខ្មែរបុរាណ។ បន្ទាប់មក ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលដល់ក្នុងរដ្ឋធានីនិងបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង។ លោកវណ្ណម៉ូលីវណ្ណ ដែលបានរស់រានជីវិតពីរបបខ្មែរក្រហមដោយបាននិរទេសខ្លួនក្នុងប្រទេសស្វីស បានវិលត្រឡប់មកកម្ពុជាវិញក្នុងឆ្នាំ១៩៩១។ សព្វថ្ងៃ កេរតំណែលរបស់គាត់ស្ថិតនៅក្រោមការគំរាមកំហែង ដោយសារតែការរីកដុះដាលនៃសំណង់ជាបន្តបន្ទាប់ក្នុងប្រទេសកម្ពុជា។ Helen Grant–Ross ដែលជាប្រវត្តិវិទូនិងជាស្ថាបត្យករ រួមជាមួយអ្នកផលិតភាពយន្តគឺ Nico Mesterharm បានសម្ភាសលោកវណ្ណម៉ូលីវណ្ណនៅពេលដែលគាត់មានអាយុ៨០ឆ្នាំ ក្នុងឆ្នាំ២០០៨។ ទោះបីជាទស្សនៈរបស់ស្ថាបត្យករឆ្នើមស្តីពីការអភិវឌ្ឍន៍ភ្នំពេញនាពេលបច្ចុប្បន្ននៅតែត្រូវបានគេស្តាប់ដោយគោរពក៏ដោយ ក៏កម្រមានអ្នកចាត់វិធានការទាំងនេះណាស់"។ ជាភាសាអង់គ្លេសជាមួយភាសាខ្មែរខ្លះ។

**<u>កំពុងដំណើរការ</u>**
ថ្ងៃទី១៣ មិថុនា ដល់ ៥ កញ្ញា | ម៉ោង១០.០០ ព្រឹក ដល់ ៥.០០ល្ងាច
នៅ ស ស បាសាក់
ផ្ទះលេខ១៨២ ផ្លូវសុធារស ភ្នំពេញ

ជាចំណែកមួយនៃ *គម្រោងវណ្ណម៉ូលីវណ្ណ៖ រដូវក្តៅ២០១៥,* សូមចូលរួមកែកាយក្នុងបន្ទប់បញ្ចាំង ជាមួយនឹងស្នាដៃជាច្រើនមកពីអតីតកាលនិងបច្ចុប្បន្នកាល ដែលផ្តល់នូវបរិបទជុំវិញប្រវត្តិសាស្រ្តទីក្រុងភ្នំពេញ និងស្ថាបត្យកម្មខ្មែរថ្មី។ ជាភាសាខ្មែរ ដោយមានការបកប្រែជាភាសាអង់គ្លេស។

**<u>ការធ្វើដំណើរទស្សនាស្ទូឌីយ៉ូថ្ងៃសៅរ៍</u>**

សម្រាប់ទស្សនិកជនដែលមានបំណងស្តាប់អំពីការងារលម្អិតនៃកម្មវិធីរដូវក្តៅឆ្នាំ២០១៥ នេះដោយផ្ទាល់ពីនិស្សិតនិងស្ថាបត្យកររបស់គម្រោង សូមចូលរួមការធ្វើដំណើរទស្សនាស្ទូឌីយ៉ូដែលមានរយៈពេលមួយម៉ោង នៅថ្ងៃសៅរ៍ពីសប្តាហ៍ម្តង ពេលរយៈពេលរបស់គម្រោងនេះ។ ជាភាសាខ្មែរនិងអង់គ្លេស។

២៧ មិថុនា | ម៉ោង១០.០០ - ១១.០០ ព្រឹក

១១ កក្កដា | ម៉ោង៤.០០ - ៥.០០ រសៀល

២៥ កក្កដា | ម៉ោង១០.០០ - ១១.០០ ព្រឹក

៨ សីហា | ម៉ោង៤.០០ - ៥.០០ រសៀល

២២ សីហា | ម៉ោង១០.០០ - ១១.០០ ព្រឹក

**<u>ការធ្វើដំណើរទស្សនាស្ថាបត្យកម្មថ្ងៃអាទិត្យ</u>**

ការធ្វើដំណើរទស្សនាស្ថាបត្យកម្មខ្មែរ ផ្តោតទៅលើអាគារដែលបានសាងសង់ឡើងក្រោយកម្ពុជាទទួលបានឯករាជ្យឆ្នាំ១៩៥៣ គឺរចនាបទមួយដែលត្រូវបានពណ៌នាថាជា "ស្ថាបត្យកម្មខ្មែរថ្មី" ខណៈដែលបង្កើតឡើងក្នុងបរិបទប្រវត្តិសាស្រ្តក្រុងភ្នំពេញ។ ការធ្វើដំណើរទស្សនាជាសាធារណៈជាទៀងទាត់ ធ្វើឡើងនៅរៀងរាល់សប្តាហ៍ទីពីរនិងទីបួននៃខែនិមួយៗ។ ជាភាសាអង់គ្លេស។ សម្រាប់ព័ត៌មានលម្អិតអំពីការធ្វើដំណើរ តម្លៃ និងព័ត៌មានសម្រាប់កក់ សូមចូលទៅកាន់៖ www.ka-tours.org

ថ្ងៃអាទិត្យ ទី២៨ មិថុនា ២០១៥, ម៉ោង២.៣០ រសៀល
ស្ថាបត្យកម្មខ្មែរថ្មីនៃទសវត្សឆ្នាំ១៩៦០

ថ្ងៃអាទិត្យ ទី១២ កក្កដា ២០១៥, ម៉ោង៨.៣០ ព្រឹក
កណ្តាលក្រុងភ្នំពេញ ដោយជិះស៊ីក្លូ

ថ្ងៃអាទិត្យ ទី២៦ កក្កដា ២០១៥, ម៉ោង៨.៣០ ព្រឹក
ផ្ទះនិងវីឡាទសវត្សឆ្នាំ១៩៦០ នៅទួលគោក (ជាមួយនិងអាគារ ស)

ថ្ងៃអាទិត្យ ទី៩ សីហា ២០១៥, ម៉ោង៨.៣០ ព្រឹក
កណ្តាលក្រុងភ្នំពេញ ដោយជិះស៊ីក្លូ

ថ្ងៃអាទិត្យ ទី២៣ សីហា ២០១៥, ម៉ោង៨.៣០ ព្រឹក
ផ្ទះនិងវីឡាទសវត្សឆ្នាំ១៩៦០ នៅទួលគោក (ជាមួយនិងអាគារ ស)

## អ្នកចូលរួមក្នុងគម្រោង

*គម្រោង វណ្ណ ម៉ូលីវណ្ណ៖ រដូវក្តៅ* មានការចូលរួមពីស្ថាបត្យករ និស្សិត និងអ្នកស្រាវជ្រាវកម្ពុជានិងអន្តរជាតិ។ អ្នកចូលរួមក្នុងគម្រោងនេះ រួមមាននិស្សិតនិងអ្នកបញ្ចប់ការសិក្សាមកពីស្ថាប័នដូចខាងក្រោមនេះ៖

- និស្សិតពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- សាកលវិទ្យាល័យន័រតុន, ភ្នំពេញ
- សាលារចនាថ្មី Parsons, ទីក្រុងញូយ៉ក
- សាកលវិទ្យាល័យមែលប៊ឺន, ប្រទេសអូស្ត្រាលី

ប៉ែន សេរីបញ្ញា គឺជាស្ថាបត្យករនិងជាអ្នកស្រាវជ្រាវទីក្រុង នៅភ្នំពេញ។ គាត់មានបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្មនិងនគរូបនីយវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅភ្នំពេញ (២០១២) និងទទួលបានវគ្គបណ្តុះបណ្តាលពីសាលារចនាថ្មី Parsons និងសាលាបរិស្ថានសាងសង់ នៅទីក្រុងញូយ៉ក (២០១២)។ គាត់គឺជាស្ថាបនិក *Phnom Penh Visions* ដែលជាគម្រោងមួយដើម្បីបណ្តុះការពិភាក្សាជុំវិញគំនិតថ្មីៗអំពីទីក្រុងនិងការរចនាក្នុងប្រទេសកម្ពុជា និងជាស្ថាបនិករបស់ *លំហ* ដែលជាព្រឹត្តិប័ត្រតាមអ៊ីនធឺណែត ដោយផ្តោតលើស្ថាបត្យកម្ម នគរូបនីយវិទ្យា និងការរចនាក្នុងប្រទេសកម្ពុជា, ព្រមទាំង *Genealogy of Bassac* ដែលជាគម្រោងសម្រាប់ស៊ើបអង្កេតទៅលើទម្រង់ទីក្រុងនិងលក្ខណៈនៃការបាក់បែកទីក្រុងតាមរយៈសម័យប្រវត្តិសាស្ត្រផ្សេងៗគ្នា។ គាត់គឺជាអ្នកធ្វើការស្នាក់នៅ ក្នុងគម្រោងសិល្បៈ ស ស នៅភ្នំពេញ (២០១៤), និងបានចូលរួមក្នុងកម្មវិធីធ្វើការស្នាក់នៅនិងពិពណ៌ *Rates of Exchange, Un-Compared: Contemporary Art in Bangkok and Phnom Penh* (2014-2015)។ បញ្ញា ធ្លាប់ធ្វើការឲ្យអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ធ្វើការផ្នែកទីក្រុងទាំងជាតិ ដូចជា គម្រោងវណ្ណម៉ូលីវណ្ណ ទេសចរណ៍ស្ថាបត្យកម្មខ្មែរ និងសមាគមជាងត្នោត។ គាត់បានទទួលជំនួយពីក្រុមប្រឹក្សាវប្បធម៌អាស៊ី (២០១២), និងតាមរយៈមជ្ឈមណ្ឌលអឺសវេស្ត គាត់នឹងចាប់ផ្តើមកម្មវិធីហាត់ការរបស់ក្រុមប្រឹក្សាអាមេរិច/អន្តរជាតិស្តីពីវិមាននិងទីតាំង នៅហូណូលូលូ ២០១៥។

<u>និស្សិត</u>

**សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, កម្ពុជា**

- ទុំ យូរីប៉ុល បេក្ខជនបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្មនិងនគរូបនីយវិទ្យា
- សុខ សុភាព បេក្ខជនបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្មនិងនគរូបនីយវិទ្យា

**សាកលវិទ្យាល័យន័រតុន, កម្ពុជា**

- សេង ច័ន្ទរស្មី បេក្ខជនបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្ម
- លី រ៉ូហ្សេត បេក្ខជនបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្ម

**សាលារចនាថ្មី Parsons, ទីក្រុងញូយ៉ក, សហរដ្ឋអាមេរិច**

- Jimmie Drummond, បេក្ខជនទ្វេអនុបណ្ឌិតផ្នែកស្ថាបត្យកម្ម និងម៉ាស្ទ័រផ្នែកវិចិត្រសិល្បៈរចនាពន្លឺ
- Hayley Reiter, បេក្ខជនអនុបណ្ឌិតផ្នែកស្ថាបត្យកម្ម

<u>អ្នកស្រាវជ្រាវ</u>

- Mikaela Kvan, អ្នកស្រាវជ្រាវផ្នែកទីក្រុង និងជាអ្នករចនាដែលមានមូលដ្ឋានក្នុងក្រុងញូវយ៉ក និងជាអ្នកបញ្ចប់ការសិក្សាពីសាលារចនាថ្មី Parsons

<u>**អ្នកគាំទ្រ**</u>

- **ស៊ុន ប៉ូរ៉ា, ស្ថាបត្យករដែលមានបញ្ញាប័ត្រ**ផ្នែកស្ថាបត្យកម្មនិងនគរូបនីយវិទ្យា (២០១៣) ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- លឿង សកុណា, បច្ចុប្បន្នជាបេក្ខជនអនុបណ្ឌិតផ្នែកស្ថាបត្យកម្ម នៅសាកលវិទ្យាល័យឈៀងម៉ៃ ប្រទេសថៃ។ គាត់មានបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្មនិងនគរូបនីយវិទ្យា (២០១៣) ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (២០១៣) និងបរិញ្ញាប័ត្រផ្នែកបកប្រែ ពីវិទ្យាស្ថានភាសាបរទេស (២០១១)
- វ៉េង សុបញ្ញា, បច្ចុប្បន្នជាស្ថាបត្យករនៅក្រុមហ៊ុនស្ថាបត្យករហុកកេង។ គាត់មានបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្មនិងនគរូបនីយវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (២០១៣)
- ប៊ុន ចាន់តារា, ស្ថាបត្យករ។ គាត់មានបរិញ្ញាប័ត្រផ្នែកស្ថាបត្យកម្មនិងនគរូបនីយវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (២០១២)
- Roger Nelson, បេក្ខជនបណ្ឌិតនៅសាកលវិទ្យាមែលប៊ឺន កំពុងស្រាវជ្រាវអំពីសិល្បៈនិងវប្បធម៌កម្ពុជាទំនើបនិងសហសម័យ។

**អំណរគុណចំពោះដៃគូផ្តល់មូលនិធិ**

*គម្រោង វណ្ណ ម៉ូលីវណ្ណ៖ ដេីរក្តៅ ២០១៥* អាចមានវត្តមានបានដោយមានការផ្តល់ថវិការដ៏សប្បុរសដោយ៖

- ស្ថានទូតសហរដ្ឋអាមេរិចក្នុងក្រុងភ្នំពេញ
- សាលារចនាថ្មី Parsons, ទីក្រុងញូយ៉ក

**អំណរគុណចំពោះដៃគូគាំទ្រ**

គម្រោងវណ្ណម៉ូលីវណ្ណ

មជ្ឈមណ្ឌលអឺសវេស្ត
និស្សិតពីសាកលវិទ្យាល័យវិចិត្រសិល្បៈ
សាកលវិទ្យាល័យន័រតុន, ភ្នំពេញ
ទេសចរណ៍ស្ថាបត្យកម្មខ្មែរ
លំហសម្រាប់ស្ថាបត្យកម្ម
ព្រឹត្តិបត្រលំហ www.lumhor.org
ផ្ទះមេត្តា, ភ្នំពេញ
មជ្ឈមណ្ឌលធនធានសោតទស្សន៍បុផាណា

**ព័ត៌មានលម្អិតអំពីពិពណ៌**
ពិពណ៌៖ *គម្រោងវណ្ណម៉ូលីវណ្ណ៖ រដូវក្តៅ២០១៥*
បើក៖ ថ្ងៃសៅរ៍ទី១៣ មិថុនា, ម៉ោង ៦.០០ ដល់ ៨.០០
សន្និសីទសារព័ត៌មាន៖ ថ្ងៃសៅរ៍ទី១៣ មិថុនា, ម៉ោង ៤.០០ រសៀល
កាលបរិច្ឆេទ៖ ១៣ មិថុនា ដល់ ៥ កញ្ញា ២០១៥
ម៉ោងបើក៖ ពីថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍, ពីម៉ោង ១០ ព្រឹក ដល់ ៥ រសៀល
ទីតាំង៖ ស ស បាសាក់, ផ្ទះលេខ ១៨២ ផ្លូវសុធារស ភ្នំពេញ
Web: www.sasabassac.com + www.vannmolyvannproject.org

**អំពី ស ស បាសាក់**

ស ស បាសាក់ គឺជាវិចិត្រសាល ជាមជ្ឈមណ្ឌលធនធាន និងជាបន្ទប់អាន សម្រាប់ទស្សន៍វប្បធម៌សហសម័យប្រទេសកម្ពុជា។ កម្មវិធីពិពណ៌របស់យើង ផ្អែកទៅលើការធ្វើស្នាដៃថ្មីៗដោយសិល្បករកម្ពុជានាំមុខគេ ក៏ដូចជាការរៀបចំកិច្ចសហប្រតិបត្តិការដោយផ្អែកលើដំណើរការទាំងនៅទីតាំងផ្ទាល់និងមិននៅលើទីតាំងផ្ទាល់នៃលំហរបស់យើងក្នុងទីក្រុងភ្នំពេញ។ បណ្ណាល័យនិងបន្ទប់អានរបស់យើង ផ្តល់នូវសម្ភារៈសំខាន់ៗសម្រាប់ការសិក្សានិងសម្រាប់ជាឯកសារពិគ្រោះ ដោយផ្តោតទៅលើប្រវត្តិសាស្ត្រ សិល្បៈ និងវប្បធម៌ នៅកម្ពុជានិងនៅតំបន់អាស៊ីអាគ្នេយ៍។ កម្មវិធីសាធារណៈរស់រវើកជាពីរភាសា គឺភាសាខ្មែរនិងភាសាអង់គ្លេស រួមមាន ការរៀបចំការជួបជុំ ការពិភាក្សារបស់សិល្បករ ការបោះពុម្ពផ្សាយ សិក្ខាសិលាសម្រាប់កុមារ ការបញ្ចាំងខ្សែភាពយន្ត និងព្រឹត្តិការណ៍កើតឡើងផ្សេងៗទៀត។ យើងធ្វើជាដៃគូជាមួយស្ថាប័ន, កម្មវិធីស្នាក់នៅនិងធ្វើការងារ, សារមន្ទីរ និងវិចិត្រសាល នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ, ពង្រីកបណ្តាញនិងចំណេះដឹងសម្រាប់សិល្បករ និងទស្សនិកជន។ ស ស បាសាក់ គឺជាសមាគមមិនរកប្រាក់ចំណេញដែលបានចុះបញ្ជីផ្លូវការ ត្រូវបានសហការបង្កើតឡើងក្នុងឆ្នាំ២០១១ ដោយបណ្តាសិល្បករស្មារសិល្បៈ និងនាយកផ្នែកសិល្បៈនិងអ្នករៀបចំពិពណ៌ Erin Gleeson ។ រាល់ការពិពណ៌ ព្រឹត្តិការណ៍ និងកម្មវិធីទាំងអស់មិនមានការគិតកម្រៃពីទស្សនិកជនទាំងអស់។ លំហដែលគ្រប់គ្រងដោយសិល្បករជាដៃគូរបស់យើង គឺគម្រោងសិល្បៈ ស ស។

**ទំនាក់ទំនង**

ប៉ែន សេរីបញ្ញា អ្នកដឹកនាំការស្រាវជ្រាវ នៃ *គម្រោងវណ្ណម៉ូលីវណ្ណ៖ រដូវក្តៅ២០១៥*
pagnaserey@gmail.com

Erin Gleeson, នាយកផ្នែកសិល្បៈ នៅ ស ស បាសាក់
erin@sasabassac.com

មឿង មេត្តា, អ្នកគ្រប់គ្រងគម្រោងសហគមន៍ នៅ ស ស បាសាក់
meta@sasabassac.com

**ការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយកន្លងមក**

**<u>ព័ត៌មានសំខាន់តាមសារព័ត៌មាន</u>**

*ការកសាងប្រទេសកម្ពុជា៖ ស្ថាបត្យកម្មខ្មែរថ្មី* ដោយ Helen Grant-Ross និង Daryl Collins

កំណត់ត្រាដ៏ទូលំទូលាយបំផុតនៃស្ថាបត្យកម្មកម្ពុជានាទសវត្សឆ្នាំ១៩៥០, ១៩៦០ និងដើមទសវត្សឆ្នាំ១៩៧០

- អាចស្វែងរកបាន និងអាចអានបាននៅ ស ស បាសាក់
- មើលតាមប្រព័ន្ធអ៊ីនធឺណែត៖http://newsgroups.derkeiler.com/Archive/Soc/soc.culture.cambodia/2007-10/msg00340.html

*Perspecta* 45: "ទីភ្នាក់ងារ" បណ្ណាធិការដោយ Kurt Evans, Iben Falconer និង Ian Mills.

- ព្រឹត្តិប័ត្រស្រាវជ្រាវផ្នែកស្ថាបត្យកម្មមនាំមុខគេ បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យយ៉េល។ ព្រឹត្តិប័ត្រលេខនេះ រួមមានការសម្ភាសជាមួយលោកវណ្ណ ម៉ូលីវណ្ណ, និងអត្ថបទសំណេរដោយប្រវត្តិវិទូសិល្បៈធ្វើការនៅខេត្តសៀមរាបឈ្មោះ Darryl Collins ដែលមានចំណងជើងថា "វណ្ណម៉ូលីវណ្ណ៖ ការកំណត់ស្នាដៃរបស់ស្ថាបត្យករដែលមានឥទ្ធិពលបំផុតរបស់ប្រទេសកម្ពុជា"
- ព្រឹត្តិប័ត្រស្រាវជ្រាវនេះអាចស្វែងរកបាន និងអាចអានបាននៅ ស ស បាសាក់ និងអាចទិញបានតាមអ៊ីនធឺណែត Amazon

*ទីក្រុងដែលគាត់បានកសាង* ដោយ (២០០៥, ថ្ងៃទី១៥ ខែឧសភា) *The New York Times*

www.nytimes.com/2005/05/15/magazine/15CAMBODIA.html

**<u>សារព័ត៌មានដទៃទៀត</u>**

ការសិក្សានៅរដូវក្តៅ ឆ្នាំ ២០១៥ បង្ហាញពីស្នាដៃរបស់លោក វណ្ណ ម៉ូលី ដោយ វិចិត្រ
(10 June 2015) ដំណឹងក្នុងស្រុក

http://www.cen.com.kh/local/02477416

សន្និសីទសារព័ត៌មានស្តីពីការសម្ពោធ គំរោងវណ្ណ ម៉ូលីវណ្ណ ៖ ការសិក្សានៅរដូវក្តៅ ឆ្នាំ ២០១៥ ដោយ សាន វាសនា (10 June 2015) ហ្សងមាស

http://hangmeasdaily.com/index.php/2014-09-08-02-22-14/5938-2015-06-10-08-27-23

ស្ថានទូតអាមេរិក ធ្វើសន្និសីទ សារព័ត៌មាន ស្តីពីការសម្ពោធ គម្រោងវណ្ណ ម៉ូលីវណ្ណ ដោយដើមអម្ពិល (10 June 2015)
http://www.dap-news.com/2011-06-14-02-39-55/93013-2015-06-10-10-02-54.html

វណ្ណម៉ូលីវណ្ណ៖ កេរដំណែលរបស់ខ្ញុំនឹងបាត់បង់ ដោយ by Claire Knox (២០១៣, ថ្ងៃទី២៥ ខែមករា) ភ្នំពេញប៉ុស្តិ៍
http://www.phnompenhpost.com/7days/vann-molyvann-my-legacy-will-disappear

ស្នាដៃអស្ចារ្យសម័យទំនើប ដោយ Tom Vater (២០១០, ថ្ងៃទី២៨ ខែឧសភា) The Wall Street Journal
http://www.wsj.com/articles/SB10001424052748704113504575265531678205848 - articleTabs=article

ការស្រម័យឡើងវិញអំពីប្រទេសកម្ពុជា ដោយ Dianne Janes (២០០៩, ថ្ងៃទី១៨ ខែសីហា) ភ្នំពេញប៉ុស្តិ៍
http://www.phnompenhpost.com/index.php/2009081827819/Life-Style/reimagining-cambodia.html

ស្ថាបត្យកម្មខ្មែរថ្មីរបស់ប្រទេសកម្ពុជា ដោយ Ron Gluckman (២០០៨ ខែមិនា) វិទ្យាស្ថានដែនដីទីក្រុង
http://www.gluckman.com/Cambodian%20Architecture.htm

រង្វាន់សម្រាប់ការកសាងប្រទេសកម្ពុជា៖ ស្ថាបត្យកម្មខ្មែរថ្មី (២០០៦, ថ្ងៃទី១៦ ខែធ្នូ) Time Magazine
http://content.time.com/time/magazine/article/0,9171,1570746,00.html

មរតកខ្មែរទំនើបកំពុងស្ថិតក្នុងគ្រោះថ្នាក់ (២០០៣, ថ្ងៃទី១០ ខែវិច្ឆិកា) Khmer Connection
http://khmerconnection.com/topic/modern-khmer-heritage-in-peril-16448/